01584900

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

ឯកសារ D362/4

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/២/០៧-០៩-២០០៩-អវតក/កសចស (អបជ ៥៨)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម និយ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 09 / 2018
ម៉ោង (Time/Heure): 10:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

សាធារណៈ

## សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំពន្យារពេលកំណត់ និងចំនួនទំព័រ

---

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តី អោ អាន:**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Daniel MCLAUGHLIN
Nushin SARKARATI

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ទទួលបាន "សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២" ដែលក្រុមសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីក្រុមទី១") បានដាក់នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ("សំណើសុំទី១")[1] និង "សារណាចូលរួម និងផ្តល់ការគាំទ្របន្ថែមទៅលើ "សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២" ដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុមទៀត ("សហមេធាវីក្រុមទី២") បានដាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ("សំណើសុំទី២")[2]។

## I. ប្រវត្តិនីតិវិធី

១. ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាដំណោះស្រាយរបស់គាត់[3] ជាភាសាខ្មែរ ដោយលើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន។ ដោយឡែក សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយរបស់គាត់ (ដីកាចោទប្រកាន់បញ្ជូន

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ដាក់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ជូនដំណឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/1 ("សំណើសុំទី១ (ឯកសារ D362/1)")។

[2] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អវតក/កសចស ("សំណុំរឿង ០០៤/២") សារណាចូលរួម និងផ្តល់ការគាំទ្របន្ថែមទៅលើ "សំណើជាបន្ទាន់របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារពេល និងបន្ថែមចំនួនទំព័រ ក្នុងការដាក់បណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងសេចក្តីសម្រេចពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២" ដាក់នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ និងជូនដំណឹងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/2 ("សំណើសុំទី១ (ឯកសារ D362/2)")។

[3] សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន ចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ តែជាភាសា ខ្មែរប៉ុណ្ណោះ ឯកសារ D359។

រឿងទៅជំនុំជម្រះ)[4] ជាភាសាអង់គ្លេស។ ពុំមានដីកាណាមួយត្រូវបានបកប្រែជាភាសាផ្លូវការផ្សេងទៀតនៃ អ.វ.ត.ក នោះទេ។

២. នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាសម្រេចច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាភាសាខ្មែរ[5] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("ដីកាសម្រេចលើភាពអាចទទួលយកបាន") ជាភាសាអង់គ្លេស និងភាសាខ្មែរ[6]។ នៅក្នុងឧបសម្ព័ន្ធ ក និង ឧបសម្ព័ន្ធ ខ ភ្ជាប់ជាមួយដីកាសម្រេចលើភាពអាចទទួលយកបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញសំអាងហេតុនៃការសម្រេចទទួលស្គាល់ និងមិនទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[7]។

៣. នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ សហមេធាវីក្រុមទី១ បានដាក់សំណើសុំទី១ ហើយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ សហមេធាវីក្រុមទី២ បានដាក់សំណើសុំទី២។

៤. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះបានណែនាំភាគីតាមអ៊ីមែល ឱ្យដាក់ចម្លើយតបទៅនឹងសំណើសុំនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ឱ្យបានមុនម៉ោង ១២ ថ្ងៃត្រង់។ នៅថ្ងៃទី២៧

---

[4] សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) ចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ តែជាភាសាអង់គ្លេសប៉ុណ្ណោះ ឯកសារ D360។

[5] សំណុំរឿង ០០៤/២ ដីកាសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ជាភាសាខ្មែរតែប៉ុណ្ណោះ ឯកសារ D361។

[6] សំណុំរឿង ០០៤/២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅ ក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362 ("ដីកាសម្រេចលើភាពអាចទទួលយកបាន (ឯកសារ D362)")។

[7] សំណុំរឿង ០០៤/២ ឧបសម្ព័ន្ធ ក នៃដីកាសម្រេចលើភាពអាចទទួលយកបាន(ឯកសារ D362)៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362.1។ សំណុំរឿង ០០៤/២ ឧបសម្ព័ន្ធ ខ នៃដីកាសម្រេចលើភាពអាចទទួលយកបាន (ឯកសារ D362)៖ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលស្គាល់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362.2។

ខែសីហា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបដោយបានលើកឡើងថា គាត់ពុំបានជំទាស់ទៅនឹងសំណើសុំទាំងនោះទេ[8]។

## II. សេចក្តីសន្និដ្ឋាន

៥. នៅក្នុងសំណើសុំទី១ សហមេធាវីក្រុមទី១ ស្នើសុំអង្គបុរេជំនុំជម្រះ (ក) ពន្យារកាលបរិច្ឆេទកំណត់ដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ ៣០ ថ្ងៃ (ខ) បង្កើនចំនួនទំព័រនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ ៤៥ ទំព័រ និង (គ) អនុញ្ញាតឱ្យសហមេធាវីដាក់បណ្តឹងឧទ្ធរណ៍តែមួយភាសាសិន ពោលគឺ ភាសាអង់គ្លេស ឬ ភាសាខ្មែរ ហើយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[9]។ សហមេធាវីទាំងនេះផ្តល់ទឡ្ហីករណ៍ថា វាជាប្រយោជន៍នៃយុត្តិធម៌ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវទទួលបានឱកាសប្រកបដោយអត្ថន័យ សមស្រប យុត្តិធម៌ និងឱកាសពិនិត្យមើលឯកសារផ្សេងៗបាន ដើម្បីអាចឆ្លើយតបទៅនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើពាក្យសុំរបស់ពួកគេស្នើសុំចូលរួមនៅក្នុងសំណុំរឿង ០០៤/០២ ជាដើមបណ្តឹងរដ្ឋប្បវេណី[10]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា នីតិវិធីដែលមានចែងនៅក្នុងវិធាន ២៣*ស្ទួន* និង វិធាន ៧៧*ស្ទួន* ចែងបើកលទ្ធភាពឱ្យប្តឹងឧទ្ធរណ៍ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ ប៉ុន្តែ ក្នុងករណី ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានសម្រេចរួមគ្នាតែម្តងដូចករណីនេះ "វាបង្ខំឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំអាចមានលទ្ធភាពរៀបចំបណ្តឹងឧទ្ធរណ៍ឱ្យបានលឿនសម្រាប់កូនក្តីរាប់ពាន់នាក់នោះទេ"[11]។ ក្រោយពីពិនិត្យមើលការសម្រេចច្រានចោលមានចំនួនច្រើនពេក ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកាន់តែមានធនធានតិចទៅៗ ការពន្យារពេលរហូតដល់ ៣០ ថ្ងៃ អាចនឹងផ្តល់លទ្ធភាពសមស្របអាចឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេនីជួបពិគ្រោះយោបល់ប្រកបដោយអត្ថន័យដើម្បីរៀបចំ

---

[8] សំណុំរឿង ០០៤/២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំចំនួនពីររបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ពួកគេ ជំទាស់នឹងដីកាសម្រេចលើភាពអាចទទួលយកបានរបស់ សចសអ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362/3។

[9] សំណើសុំទី១ (ឯកសារ 362/1) កថាខណ្ឌ ១៤។

[10] សំណើសុំទី១ (ឯកសារ 362/1) កថាខណ្ឌ ៩។

[11] សំណើសុំទី១ (ឯកសារ 362/1) កថាខណ្ឌ ១០។ *សូមមើលផងដែរ* កថាខណ្ឌ ៦។

បណ្ដឹងឧទ្ធរណ៍ ដែលចាំបាច់ក្នុងការធានាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការចូលរួមឲ្យបានពេញលេញ[12]។ សំណើសុំទី១ សន្និដ្ឋានបញ្ចប់ថា ការយល់ព្រមពន្យាររយៈពេលនឹងមិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីផ្សេងទៀត ឬ បន្ថយប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ហើយវានឹងធានាថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនឹងទទួលបានយុត្តធម៌គោរពទៅតាមនីតិវិធីអនុវត្តលើបណ្ដឹងឧទ្ធរណ៍របស់ពួកគេស្ដីពីភាពអាចទទួលយកបាន[13]។

៦. សហមេធាវីក្រុមទី២ ទំនងជា "ចូលរួមសន្និដ្ឋាន" ដូចសំណើសុំទី១ ដោយបានយល់ស្របតាមសេចក្ដីសន្និដ្ឋានទាំងនោះ[14]។ សំណើសុំទី២ លើកឡើងសាជាថ្មីអំពីការអំពាវនាវនៅក្នុងសំណើសុំទី១ ស្នើសុំបង្កើនចំនួនទំព័រ ហើយនឹងស្នើសុំការអនុវត្តដាក់បណ្ដឹងឧទ្ធរណ៍តែមួយភាសាសិន ដោយការបកប្រែនឹងដាក់ជូនតាមក្រោយ។ ទោះបីជាយ៉ាងនេះក៏ដោយ ពាក់ព័ន្ធនឹងការពន្យារពេល សហមេធាវីក្រុមទី២ ស្នើសុំអង្គបុរេជំនុំជម្រះពន្យារកាលបរិច្ឆេទកំណត់ដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ រហូតដល់ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសំណៅភាសាខ្មែរនៃដីកាដំណោះស្រាយ (ដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ)[15]។ យោងតាមមាត្រា ៨.៥ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក ("សេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ") វិធាន ២១ និងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង[16] សហមេធាវីផ្ដល់ទឡ្ហីករណ៍ថា ការពន្យាររយៈពេលនេះមានយុត្តិកម្មសមស្របផ្អែកលើមូលដ្ឋានថា ដីកាដំណោះស្រាយ (ដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតត្រូវបានចេញជាភាសាអង់គ្លេសតែប៉ុណ្ណោះ[17]។ ដោយហេតុថា ការសម្រេចនៅក្នុងដីកាសម្រេចស្ដីពីភាពអាចទទួលយកបាន ផ្អែកមូលដ្ឋានលើដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ អាស្រ័យហេតុនេះ "លទ្ធភាពរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការការពារប្រកបដោយប្រសិទ្ធភាពលើសិទ្ធិរបស់កូនក្ដី ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ តាមរយៈដំណើរការបណ្ដឹងឧទ្ធរណ៍លើភាពអាចទទួល

---

[12] សំណើសុំទី១ (ឯកសារ 362/1) កថាខណ្ឌ ១០-១១។ *សូមមើលផងដែរ* កថាខណ្ឌ ៧-៨។

[13] សំណើសុំទី១ (ឯកសារ 362/1) កថាខណ្ឌ ១២-១៣។

[14] សំណើសុំទី២ (ឯកសារ 362/2) កថាខណ្ឌ ១, ៧។

[15] សំណើសុំទី២ (ឯកសារ 362/2) កថាខណ្ឌ ៧។

[16] សំណើសុំទី២ (ឯកសារ 362/2) កថាខណ្ឌ ៤។

[17] សំណើសុំទី២ (ឯកសារ 362/2) កថាខណ្ឌ ២។

យកបាន អាស្រ័យលើការយល់ដឹងច្បាស់លាស់អំពីវិសាលភាពនៃដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ"។ ហេតុដូច្នេះ នៅពេលគិតរាប់រយៈពេលវេលានៃបណ្តឹងឧទ្ធរណ៍ខណៈដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះមានតែមួយភាសា គឺជាការគម្រាមកំហែង និងធ្វើឱ្យខាតប្រយោជន៍ដល់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកម្ពុជា និងកូនក្តីរបស់ពួកគេ ហើយគឺជាការរំលោភគោលការណ៍ជាសារវ័ន្តនៃភាពយុត្តិធម៌ផ្នែកនីតិវិធី[18]។

## III. កិច្ចពិភាក្សា

### ក. ការពន្យារពេល

៧. អង្គបុរេជំនុំជម្រះបានរកឃើញយ៉ាងជាក់លាក់ថា "ការណែនាំអាចរកឃើញនៅក្នុងគោលការណ៍ទូទៅស្តីពីជនរងគ្រោះ ដូចមាននៅក្នុងច្បាប់អន្តរជាតិ" រួមទាំងគោលការណ៍ណែនាំជាមូលដ្ឋាន អ.ស.ប ស្តីពីជនរងគ្រោះ[19]។ គោលការណ៍ទាំងនេះគូសបញ្ជាក់ថា ជនរងគ្រោះគួរមានសិទ្ធិទទួលបានយុត្តិធម៌ត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព[20] ហើយជនរងគ្រោះគួរមានលទ្ធភាពបង្ហាញ "ការយល់ឃើញ និងការព្រួយបារម្ភ [...] នៅក្នុងដំណាក់កាលសមស្របនៃកិច្ចដំណើរការនីតិវិធី

---

[18] សំណើសុំទី២ (ឯកសារ 362/2) កថាខណ្ឌ ៥-៦។

[19] សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០៤/២") សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4)") កថាខណ្ឌ ៣២ (លេខយោងជើងទំព័រលុបចោ) យោងលើ មហាសន្និបាត អ.ស.ប សេចក្តីប្រកាសស្តីពីគោលការណ៍ទូទៅនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការបំពានអំណាច ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ ឯកសារ អ.ស.ប លេខ A/RES/40/34 ("សេចក្តីប្រកាស អ.ស.ប ស្តីពីជនរងគ្រោះ")។ មហាសន្និបាត អ.ស.ប គោលការណ៍ទូទៅ និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានឧបាស្រ័យ និងសំណងសម្រាប់ជនរងគ្រោះនៃអំពើរំលោភធ្ងន់ធ្ងរនៃច្បាប់មសិទ្ធិមនុស្សអន្តរជាតិ និងការរំលោភធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៦ ឯកសារលេខ A/RES/60/147 ("គោលការណ៍មូលដ្ឋាន អ.ស.ប")។

[20] ជារួមសូមមើល សេចក្តីប្រកាស អ.ស.ប ស្តីពីជនរងគ្រោះ គោលការណ៍ទី ៤-៦។ គោលការណ៍មូលដ្ឋាន អ.ស.ប គោលការណ៍ទី ១១។

ដែលផលប្រយោជន៍បុគ្គលត្រូវបានប៉ះពាល់ ដោយពុំបង្កព្យសនកម្មដល់ជនជាប់ចោទ និងស្រប តាមប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាតិពាក់ព័ន្ធ”[21]។

៨. ម្យ៉ាងវិញទៀត វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងតម្រូវថា “ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង [និង] សេចក្តីណែនាំអនុវត្ត [...] ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការ នីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា”។ ដូចអង្គបុរេជំនុំជម្រះធ្លាប់បានកត់សម្គាល់នាពេលមុន៖

> កិច្ចព្រមព្រៀង [អ.វ.ត.ក] បានចែងថា គោលការណ៍ជាសារវ័ន្តមួយ ក្នុងការបង្កើត អ.វ.ត.ក គឺ “ការបង្រួបបង្រួមជាតិ”។ ចំណុចនេះជាការបង្ហាញដល់ចៅក្រម ក៏ដូចជាអង្គជំនុំជម្រះនៅ អ.វ.ត.ក ឱ្យស្វែងរកទាំងការពិតស្តីពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ជាពិសេស និងការធានាថា មានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ[22]។

៩. ទោះបីជាវិធាន ៧៧*ស្ទួន* ហាមឃាត់ការពន្យាររយៈពេលរហូតដល់ ១០ ថ្ងៃ ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏អង្គបុរេជំនុំជម្រះយល់ឃើញថា ការខកខានមិនបានពន្យាររយៈពេលកំណត់ខ្លីបែបនេះនៅក្រោមកាលៈទេសៈបច្ចុប្បន្ន ពោលគឺ ក្នុងពេលដែលសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានកូនក្តីរាប់ពាន់នាក់ ដែលពាក្យសុំរបស់ពួកគេត្រូវបានច្រានចោលនៅក្នុងពេលជាមួយគ្នា នឹងជាការរារាំងមិនឱ្យជនរងគ្រោះចូលរួមប្រកបដោយប្រសិទ្ធភាព ហើយរំលោភលើវិធាន ២១ នៃវិធានផ្ទៃក្នុង និងគោលការណ៍អន្តរជាតិស្តីពីការធានានូវផលប្រយោជន៍របស់ជនរងគ្រោះ។ ការពន្យាររយៈពេលមានភាពចាំបាច់អាចឱ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពិគ្រោះយោបល់បានគ្រប់គ្រាន់ជាមួយនឹងកូនក្តីរបស់ខ្លួន ដែលផលប្រយោជន៍របស់ពួកគេបានទទួលរងផលប៉ះពាល់ដោយសារដីកាសម្រេចស្តីពីភាពអាចទទួលយកបាន ដើម្បីត្រៀមរៀបចំបណ្តឹងឧទ្ធរណ៍។

---

[21] សេចក្តីប្រកាស អ.ស.ប ស្តីពីជនរងគ្រោះ គោលការណ៍ទី ៦(ខ)។

[22] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីភាពទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D404/2/4) កថាខណ្ឌ ៦៥។

១០. ចំពោះការពន្យាររយៈពេលប៉ុន្មាននោះ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ការសម្រេចនៅក្នុងដីកាសម្រេចស្តីពីភាពអាចទទួលយកបាន ដែលអាចជាដីកាដងការជំទាស់នៅក្នុងករណីនេះ បានសំអាងលើសំអាងហេតុនៅក្នុងដីកាដំណោះស្រាយ (ដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ)[23] ដែលបានចេញជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ហេតុដូច្នេះ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកម្ពុជាមិនមានលទ្ធភាពរៀបចំបណ្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាពរហូតទល់តែមានការចេញសំណៅជាភាសាខ្មែរនៃដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) ជាមុនសិន។ យោងតាមកាលៈទេសៈទាំងនេះ ហើយអនុលោមតាមវិធាន ៣៩(២) អង្គបុរេជំនុំជម្រះយល់ឃើញថា វាយុត្តិធម៌ និងសមហេតុផលក្នុងការពន្យាររយៈពេលកំណត់ក្នុងការដាក់បណ្តឹងឧទ្ធរណ៍លើដីកាសម្រេចស្តីពីភាពអាចទទួលយកបានរហូតដល់ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសំណៅជាភាសាខ្មែរនៃដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ)។

## ខ. ចំនួនទំព័រកំណត់

១១. អង្គបុរេជំនុំជម្រះក៏ត្រូវបានស្នើសុំពីភាគីឱ្យបង្កើនចំនួនទំព័រកំណត់នៃបណ្តឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ ៤៥ ទំព័រ[24]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការបង្កើនចំនួនទំព័រនេះមានភាពសមស្រប អនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ក្រោយពីពិចារណាឃើញថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចនឹងប្តឹងឧទ្ធរណ៍ មានចំនួនច្រើន[25]។

## គ. ការដាក់ឯកសារតែមួយភាសាសិន

១២. ចំណុចចុងក្រោយ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ ផ្តល់ការអនុញ្ញាតឱ្យពួកគេដាក់បណ្តឹងឧទ្ធរណ៍តែមួយភាសាសិន ពោលគឺ ភាសាខ្មែរ ឬ ភាសាអង់គ្លេស

---

[23] សូមមើល ខ. ដីកាសម្រេចស្តីពីភាពអាចទទួលយកបាន (ឯកសារ D362) កថាខណ្ឌ ៣៧។

[24] សំណើសុំទី១ (ឯកសារ D362/1) កថាខណ្ឌ ១៤។ សំណើសុំទី២ (ឯកសារ D362/2) កថាខណ្ឌ ៧។

[25] សូមមើលប្រៀបធៀបជាមួយ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ស្ពឺ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D411/3/2 កថាខណ្ឌ ២។

ដោយការបកប្រែនឹងដាក់ជូនតាមក្រោយ[26]។ អនុលោមតាមមាត្រា ៧.២ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ អង្គបុរេជំនុំជម្រះយល់ព្រមតាមសំណើសុំ។

## IV. ផ្នែកសម្រេចសេចក្ដី

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

- **ពន្យារ** រយៈពេលកំណត់ដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ រហូតដល់ ៣០ ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ) ជាភាសាខ្មែរ។

- **បង្កើន** ចំនួនទំព័រកំណត់សម្រាប់សេចក្ដីសន្និដ្ឋាននៃបណ្ដឹងឧទ្ធរណ៍លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២ រហូតដល់ ៤៥ ទំព័រ ជាភាសាអង់គ្លេស ឬ បារាំង ឬ ៩០ ទំព័រ ជាភាសាខ្មែរ។

- **អនុញ្ញាតឲ្យ** សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដាក់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនតែមួយភាសាសិន អាចជាភាសាអង់គ្លេស ឬ ភាសាខ្មែរ ដោយការបកប្រែទៅជាភាសាផ្សេងទៀតត្រូវដាក់ជូនតាមក្រោយ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន័យ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

---

[26] សំណើសុំទី១ (ឯកសារ D362/1) កថាខណ្ឌ ១៤។ សំណើសុំទី២ (ឯកសារ D362/2) កថាខណ្ឌ ៧។